# វគ្គទី ១
# ភូមិកំណើតខ្ញុំ
# ( ទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០ )

ខ្ញុំកើតនៅភូមិស្នាយពល ក្នុងឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង នៅឆ្នាំ ១៩៥០ គឺជាងហុកសិបឆ្នាំមកហើយ ។ ភូមិស្នាយពល ជាទីរួមស្រុកនៃស្រុកពារាំង ដែលស្ថិតនៅ ផ្នែកបូព៌ានៃប្រទេសកម្ពុជា ។ នៅពេលនោះ ភូមិនេះមានប្រជាពលរដ្ឋតែ ៥០០ ឬ ៦០០ នាក់ប៉ុណ្ណោះ ។ ភូមិស្នាយពលមានចំងាយប្រហែល ៧០ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែដោយសារហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកគមនាគមន៍មិនល្អ ការធ្វើដំណើរពីរាជធានីភ្នំពេញមានការលំបាកជាខ្លាំង ។

ដើម្បីបានជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយ ខ្ញុំសូមបង្ហាញអំពីព្រឹត្តិការណ៍ជាតិ និង អន្តរជាតិខ្លះៗ ក្នុងបរិបទប្រវត្តិសាស្ត្រនៅសម័យនោះ ដែលមានការពាក់ព័ន្ធនឹងចំណុចនានាជាបន្តបន្ទាប់ ។

ប្រទេសកម្ពុជាជាប្រទេសមួយនៅក្នុងឧបទ្វីបឥណ្ឌូចិន ។ ឥណ្ឌូចិនជាតំបន់មួយនៅចន្លោះឥណ្ឌា និង ចិន ដែលមានប្រទេសភូមា ថៃ ឡាវ វៀតណាម និង កម្ពុជា ។ ប៉ុន្តែចាប់ពីសម័យអាណានិគមកម្មបារាំង (Colonisation française/ French colonization) នៅពាក់កណ្តាលសតវត្សទី១៩ គេសម្គាល់ឥណ្ឌូចិនចំពោះតែបីប្រទេសគឺ កម្ពុជា វៀតណាម និង ឡាវ ដែលនៅសម័យនោះ គេនិយមហៅថា ឥណ្ឌូចិនបារាំង (Indochine française)[1] ។

---

[1] French Indochina was part of the French colonial empire in Southeast Asia. ឥណ្ឌូចិនបារាំង ជាផ្នែកមួយនៃចក្រភពអាណានិគមបារាំងនៅតំបន់អាស៊ីអាគ្នេយ៍ ។

សង្គ្រាមឥណ្ឌូចិនលើកទី១ (Première Guerre d'Indochine)[2] ដែលជាសង្គ្រាមរវាងប្រទេសទាំងបីខាងលើដើម្បីទាមទារឯករាជ្យពីប្រទេសបារាំង បានចាប់ផ្តើមនៅឆ្នាំ ១៩៤៦ និង បញ្ចប់នៅឆ្នាំ ១៩៥៤ ។ សន្និសីទក្រុងហ្សឺណែវ (Conférence de Genève) ពីថ្ងៃទី ៨ ឧសភា ដល់ថ្ងៃទី ២១ កក្កដា ១៩៥៤ គឺជាសន្និសីទ ដែលប្រទេសជាច្រើនបានចូលរួម ដើម្បីបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន ។ ប្រទេសទាំងបីនៅឥណ្ឌូចិនមានវាសនាខុសៗពីគ្នា៖ ប្រទេសវៀតណាមត្រូវបែងចែកជាពីរ ប្រទេសឡាវក៏មានរបបគ្រប់គ្រងពីរ ចំណែកប្រទេសកម្ពុជាមានឯកភាពទឹកដីទាំងស្រុងនៅឆ្នាំ ១៩៥៤ ។ លើសពីនេះទៀត យើងមានឯកភាពខាងនយោបាយចាប់ពីឆ្នាំ ១៩៥៥ នៅពេលដែលមានការបង្កើតចលនាសង្គមរាស្ត្រនិយម ។ យើងរស់នៅក្នុងសុខសន្តិភាព ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៥០ ក៏ប៉ុន្តែផ្លូវគមនាគមន៍នៅសម័យនោះ នៅមិនទាន់ល្អនៅឡើយទេ ។